ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤២ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារចុះត្រួតពិនិត្យបាតុភាព នៅប្រាសាទព្រះវិហារ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការ, បង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញសេចក្តីសំរេចលេខ ១៧ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-ថៃ

-យោងតាមតំរូវការចាំបាច់

## សំរេច

ប្រការ១: បង្កើតក្រុមការងារចុះត្រួតពិនិត្យបាតុភាពនៅប្រាសាទព្រះវិហារដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម វ៉ា គឹមហុង | ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន | ប្រធាន |
| ២-ឯកឧត្តម ឡុង ផុល | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |

www.pheakdeylaw.com

| | | |
|---|---|---|
| ៣-ឯកឧត្តម រស់ រ៉េន | អនុរដ្ឋលេខាធិការនៃក្រសួងទេសចរណ៍ | សមាជិក |
| ៤-ឯកឧត្តម ឡុង វិសាលោ | អនុរដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥-ឧត្តមសេនីយ៍ឯក ឈុំ សុជាតិ | នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦-ឯកឧត្តម ព្រាប តាន់ | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ៧-ឧត្តមសេនីយ៍ទោ ជា ម៉ន | មេបញ្ជាការយោធភូមិភាគ៤ | សមាជិក |
| ៨-លោក ហ៊ួន សាវ៉ាង | អគ្គនាយករងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

ប្រការ២ : ក្រុមការងារចុះត្រួតពិនិត្យបាតុភាពនៅប្រាសាទព្រះវិហារ មានភារកិច្ចដូចខាងក្រោម :

ក-ពិនិត្យបាតុភាពដែលកើតមានឡើងដោយភាគីថៃ ធ្វើការសាងសង់សាលាសំណាក់នៅមុខផ្លូវចូលក្នុងបរិវេណប្រាសាទព្រះវិហារ ។

ខ-ពិនិត្យនិងដោះស្រាយរាល់បញ្ហាទាក់ទងនិងការសាងសង់ដោយភាគីថៃ ដោយឈរលើគោលការណ៍ដែលគណៈកម្មការចំរុះព្រំដែនកម្ពុជា-ថៃ បានឯកភាពគ្នាក្នុងកំណត់ហេតុនៃកិច្ចប្រជុំលើកទី១ និងលើក ទី២ ។

គ-ចរចាជាមួយភាគីថៃ ដើម្បីរក្សាស្ថានភាពដដែល នៅតំបន់ប្រាសាទព្រះវិហារ ដោយចៀសវាងធ្វើសកម្មភាពណាដែលនាំឱ្យប៉ះពាល់ដល់ខ្សែព្រំដែនអន្តរជាតិរវាងប្រទេសទាំងពីរ នៅក្នុងតំបន់នោះ ។

ឃ-ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ និងការចរចាជាមួយភាគីថៃ ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ៣ : គ្រប់សមាជិកនៃក្រុមការងារចុះត្រួតពិនិត្យបាតុភាពនៅប្រាសាទព្រះវិហារ ត្រូវចូលប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ៤ : ក្រុមការងារនេះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

www.pheakdeylaw.com

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងសេចក្តីសំរេចនេះ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ៥*

*-កាលប្បវត្តិ-ឯកសារ*

www.pheakdeylaw.com